អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងរង្វង់ទឹកមុខ**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**សិក្សាសង្គម**

ការយល់ដឹងអំពីខ្លួនឯង(ស្គាល់ពីអារម្មណ៍មួយចំនួន)

(សម្តែងអារម្មណ៍ និងចេះសង្កត់ចិត្តរបស់ខ្លួន)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(សិក្សាសង្គម)** ប្រាប់បានពីអារម្មណ៍ ឬឥរិយាបថនៃការព្រួយបារម្មណ៍ កង្វល់ក្នុងព្រឹត្តិការណ៍មួយចំនួន។

ប្រាប់បានពីអារម្មណ៍របស់ខ្លួននៅពេលជួបរឿងមិនសប្បាយចិត្ត និងសប្បាយចិត្តដោយការធ្វើកាយវិការ ទឹកមុខ និងពាក្យសម្តី។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ កាតអារម្មណ៍ (ពណ៌ / សខ្មៅ)

**ការរៀបចំ** ៖ សម្រេចចិត្តថាតើអារម្មណ៍មួយណាដែលអ្នកចង់បង្រៀនទៅក្មេងៗ សប្បាយរីករាយ ក្រៀមក្រំ ភ័យខ្លាច ខឹង រំភើប -ល-។

**សេចក្តីណែនាំ៖**

1. និយាយថា៖ កូនៗថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងរង្វង់ទឹកមុខ** ជាមួយកូនៗទាំងអស់គ្នា។
2. បន្ទាប់មកត្រូវធ្វើទឹកមុខតាមកាតអារម្មណ៍ និងកាយវិការម្តង១ រហូតអស់ទឹកមុខទាំង៦។
3. បន្ទាប់ពីបង្ហាញកាតអារម្មណ៍ហើយ ត្រូវឱ្យក្មេងៗទាំងអស់ទាយថា៖ តើទឹកមុខហ្នឹងជាទឹកមុខអ្វី?
4. ឱ្យក្មេងៗទាំងអស់ធ្វើទឹកមុខ និងកាយវិការ តាមដោយមិនបញ្ចេញសម្លេងទេ។

5. គ្រាន់តែនិយាយដោយគ្មានសម្លេងជាមួយការលេងទឹកមុខ និងភាសាកាយវិការក្នុងការពន្យល់តែប៉ុណ្ណោះ ។
6. ជ្រើសរើសក្មេងតូចៗតាមតូច ធំតាមធំបង្កើតជាក្រុម ហើយឈរជារង្វង់។
7. ចែកកាតអារម្មណ៍ទៅកាន់ក្មេងៗម្នាក់មួយសន្លឹកៗតាមក្រុមនីមួយៗ។
8. ក្នុង ១ក្រុមក្មេងៗត្រូវទទួលបានកាតអារម្មណ៍ដូចគ្នាចំនួន ២នាក់ ។
9. អ្នកត្រូវលើកក្រដាសសន្លឹក A4 ពីទឹកមុខមួយក្នុងចំណោមទឹកមុខទាំង៦នោះឡើងបង្ហាញក្មេងៗ។
10. សួរក្មេងៗថា៖ តើកូនៗណាមានកាតទឹកមុខដូចរូបអ្នកគ្រូ?សូមកូនៗលើកបង្ហាញ។ សូមធ្វើទឹកមុខ និងកាយវិការតាមទាំងអស់ ហើយក្មេងៗអាចផ្លាស់ប្តូរ កន្លែងគ្នាបាន។
11. ត្រូវបន្តលើកសន្លឹកទឹកមុខទាំងនោះ ម្តងមួយៗ រហូតដល់ក្មេងៗទាំងអស់បានធ្វើកាយវិការ និងធ្វើទឹកមុខរបស់ពួកគេបានគ្រប់ៗគ្នា ហើយក្មេងៗទាំងអស់បានផ្លាស់ប្តូរកន្លែងគ្នាជាការស្រេច។